[*អ្នកសម្ភាសៈ សាយ តុលា.* អ្នកផ្តល់បទសម្ភាសន៍ៈ ក្រាក់ ជី]
[*Interviewer: TS.* Interviewee: KC.]

[00:00]

*[លោកតា ក្រាក់ ជី ចិត និងផ្ទាត់អង្គួចឬស្សីដែលគាត់ទើបនឹងធ្វើរួច]*
*[KC carves and flicks an unfinished Angkuoch Russey that he has just made.]*

[00:51]

*[លោកតា ក្រាក់ ជី សាកល្បងលេងអង្គួច]*
*[KC tests the Angkuoch Russey by playing it]*

[01:01]

*[លោកតា ក្រាក់ ជី ចិតអង្គួចបន្ថែមបន្ទាប់ពីតេស្តសម្លេងរបស់វា]*
*[KC carves his newly-made Angkuoch further, after testing it]*

[01:35]

*[លោកតា ក្រាក់ ជី តេស្តសម្លេងអង្គួចម្តងទៀត]*
*[KC tests the sound of the Angkuoch again]*

[01: 41]

*តើវាមានសម្លេងរលាស់ហើយឬនៅ?*
*Can it produce a resonant sound now?*

> ពេលនេះ វាមិនទាន់រលាស់ទេ ដូច្នេះ ខ្ញុំត្រូវកែតម្រូវវាថែមបន្តិចទៀត។
> It is not resonant yet so I have to do a little bit more. *[carves]*

[02:09]

> ពេលនេះ វាបានល្អហើយ។ ខ្ញុំត្រូវកែសម្រួលដោយបិតក្រប។
> Now it is okay. I have to carve its cover.
>
> តែពេលនេះ ខ្ញុំមិនមានការបិតទេ។
> But now I do not have any glue.

[02:27]

*[លោកតា ក្រាក់ ជី ចិតអង្គួចឬស្សីបន្ថែម]*
*[KC carves his Angkuoch Russey more.]*

[03:18]

*[លោកតា ក្រាក់ ជី គូសបន្ទាត់ត្រង់នៅលើតួអង្គួចដោយប្រើកាំបិត]*
*[KC makes small markings with his knife on the body of the Angkuoch]*

[03:33]

*តើតាគូសបែបនោះដើម្បីអ្វី?*
*What do you make those lines for?*

> ខ្ញុំធ្វើបែបនេះឱ្យវាស្អាត។

I make these lines to make this Angkuoch [look] beautiful.

ពេលនេះ ខ្ញុំមិនមានកាវបិតទេ។ ចាំខ្ញុំរកមើលសិន!
Now I do not have glue. Let me find it!

[03: 54]

ប៉ុណ្ណេះ ខ្ញុំអាចប្រើការបាន។
Now it is playable.

ខ្ញុំចង់បិតធ្វើសារថ្មីមួយទៀត ដើម្បីបង្ហាញឱ្យបានច្បាស់។
I want to make another one in order to show all the details.

[04:21]

*[លោកតា ក្រាក់ ជី យកខ្មៅដៃមកគូសចម្លងពីទំហំរបស់អង្គួច។]*
*[KC takes a pencil to copy and mark the size of a sample Angkuoch]*

[04:37]

*តើគាត់កំពុងគូសអ្វី?*
*What are you drawing?*

ខ្ញុំគូសសម្រាប់វាស់ខ្នាត។ បើខ្ញុំមិនគូស វានឹងមិនត្រឹមត្រូវទេ។ ដូច្នេះ ខ្ញុំត្រូវគូសវា។
I am drawing this line to copy its size. If I do not draw it, it will not be correct.
That is why I have to draw.

[05:46]

*តើនេះគឺជាអ្វី?*
*What is this?*

នេះគឺជាដែកងាប់។ ខ្ញុំប្រើវាដើម្បីចោះប្រហោង។
It is a small chisel. I use it to make a hole.

[06:00]

*[លោកតា ក្រាក់ ជី ប្រើដែកងាប់ និងញញួរដើម្បីចុះប្រហោងអង្គួច]*
*[KC uses a small chisel and hammer to make a hole in the body of the Angkuoch]*

[07:15]

*ចុះនេះគឺជាអ្វី?*
*And what is this?*

យើងហៅរបស់នេះថា «ជ្រាត់» (ដែកងាប់)។ ខ្ញុំប្រើសម្រាប់ធ្វើអណ្តាត។
I call it "Chrot" [chisel]. I use this tool to make the lamella.

[07:49]

ចោះទំលុះ!
Making a hole!

[08:09]

*តើគាត់បាច់កល់បែបនេះធ្វើអ្វី?*
*Why do you have to use this small thing to even it up like this?*

ខ្ញុំត្រូវកល់ដើម្បីបិត កុំឱ្យវាប៉ះ។ បើខ្ញុំមិនកល់ទេ ខ្ញុំមិនអាចបិតបានទេ។
I have to even up to make it not to stick to the body. If it sticks, I cannot carve it.

[08:39]

*មុននឹងគាយកកាំបិតមកចិត តើគាត្រូវពិនិត្យមើលជាមុនទេ?*
*Before you use this knife, do you have to check it's ok first?*

មើល! [ សើច...]
Yes! [ Laughs...]

*ដើម្បីធ្វើអង្គួចមួយ តើគាប្រើកាំបិតប៉ុន្មាន?*
*How many knives do you have to use to make an Angkuoch?*

ខ្ញុំមានកាំបិតបីនៅទីនេះ។ ដោយសារខ្ញុំមានកូនចៅមកជួយធ្វើ ដូច្នេះទើបខ្ញុំត្រូវការកាំបិតបី។
I have three knives here. I have three because sometimes my grandchildren and sons help me to make them.

នៅពេលដែលខ្ញុំធ្វើតែម្នាក់ឯង ខ្ញុំប្រើតែមួយទេ។
When I do it alone, I use only one knife.

[09:04]

*តើគេហៅកាំបិតដែលគាកំពុងប្រើសម្រាប់ចិតនេះយ៉ាងដូចម្តេច?*
*What do you call the knife you are using?*

មនុស្សចាស់បុរាណហៅវាថា «កាំបិតបន្ទោះ»។ ខ្ញុំមិនដឹងថា វាមានន័យយ៉ាងណាទេ។ ខ្ញុំចេះតែហៅតាមគ្នា។ គាត់ប្រាប់ខ្ញុំថា វាជាកាំបិតបន្ទោះ។
Old people call it 'bamboo-cutting knife'. I do not know what that means, yet I just imitated them. They told me that it is a bamboo cutting knife.

[10:57]

*តើគាអាចធ្វើអង្គួចបានប៉ុន្មានក្នុងមួយថ្ងៃ?*
*How many Angkuoch can you make in one day?*

ប្រហែលជា១៥!
About 15!

*តើគាចំណាយពេលប៉ុន្មាននាទីក្នុងការធ្វើអង្គួចមួយ?*
*How many minutes do you spend for making an Angkuoch?*

ខ្ញុំមិនដែលបានផ្ទៀងទេ ដូច្នេះខ្ញុំមិនដឹងថាប៉ុន្មាន។
I have never taken notice, so I do not know.

[11:37]

*តើគាដែលភ្លាត់មុតដៃដែរឬទេ?*
*Have you have had any injury while making Angkuoch?*

មានដែរ! មានភ្លាត់ដែរ!
I have! In the past.

*នៅពេលដែលតាមុតដៃ តើតាឧកកខានធ្វើរយៈពេលប៉ុន្មានដែរ?*
*When you had an injury, for how long did you stop making?*

ខ្ញុំមិនដែលខកខានទេ ដោយសារវាជារបួសតិចតួច។
I never stopped because it was just a skin injury.

វាមុតមិនធ្ងន់ធ្ងរដែរ។
It was not a big injury.

[13: 30]

*[លោកតា ក្រាក់ ជី ប្រើចៅទៅទិញកាវ]*
*[KC orders his grandson to go and buy glue]*

ទៅទិញកាវមួយភ្លែតមក! សុំលុយយាយទិញកាវ!
Please go to buy glue! Go and ask money from your grandma to buy glue!

*ហេតុអ្វីបានជាតាចាំបាច់បិតកាវ?*
*Why do you have to use glue?*

ខ្ញុំបិតដើម្បីកុំឱ្យក្របរបស់អង្គួចរត់ទៅមក។
I stick with glue to make the covers stay still.

*អ្វីដែលរត់ទៅរត់មក?*
*What moves?*

ឈប់សិន! ចាំខ្ញុំបង្ហាញថាត្រូវធ្វើបែបណា!
Wait! Let me show you!

បើយើងមិនបិតក្របនេះ វានឹងរត់ចុះឡើង!
If I do not stick it down here, it will move.

បើយើងមិនបិតក្របនេះ វានឹងរត់ចុះឡើង! ខ្ញុំត្រូវបិតទើបវាមិនរត់ទៅរត់មក។
If I do not stick it down with glue here, it will move. Therefore, I have to stick it.

[14:37]

នៅពេលដែលខ្ញុំមិនបិតកាវ ក្របនេះវានឹងរុញចូល ធ្វើឱ្យមិនលឺសម្លេង!
If I do not stick it down, the covers will move onto this, and then it would make no sound.

*នៅពេលដែលតាធ្វើហើយ តើត្រូវតេស្តសម្លេង?*
*When you have finished all the process, do you always have to test the sound of an Angkuoch?*

បាទ! ខ្ញុំត្រូវផ្ទាត់មើលសិន។ ខ្ញុំអាចយកបានលុះត្រាណាតែវាមានសម្លេងលឺ។ បើវាមិនលឺ គេនឹងមិនទិញទេ។ ដូច្នេះ ខ្ញុំត្រូវខាត។ ហើយវាពិបាកចោល!
Yes! I have to test it. I can use it if it has a good sound. If not, people will not buy it. So I would not get any benefit. I would have to throw it away.

*ដើម្បីធ្វើអង្គួចនីមួយៗ តើតាត្រូវប្រើឧបករណ៍អ្វីខ្លះ?*
*To make one Angkuoch, how many tools do you need?*

បាទ?
*Yes?*

*ដើម្បីធ្វើអង្កួចនីមួយៗ តើគាត្រូវប្រើឧបករណ៍អ្វីខ្លះ? [សួរសំណួរដដែលម្តងទៀត?]*
*To make one Angkuoch, how many tool do you need? [Question is repeated.]*

ខ្ញុំមិនត្រូវការប្រើប្រាស់ឧបករណ៍ច្រើនពេកទេ។ ខ្ញុំមានកាំបិត ឫស្សី និងកាវសម្រាប់បិត។
I do not need many tools. I use knife, bamboo and glue.

វាមិនច្រើនពេកទេ!
That's not many.

*ចុះខ្ញុំឃើញមានកូនម៉ែត្រ និងឧបករណ៍តូចៗពីរទៀត?*
*But I saw a ruler and other two tools?*

បាទ?
Yes?

*ចុះខ្ញុំឃើញមានកូនម៉ែត្រ និងឧបករណ៍តូចៗពីរទៀត? [សួរសំណួរដដែលម្តងទៀត?]*
*But I saw a ruler and other two tools? [Question is repeated.]*

ខ្ញុំមានដែកដាប់តូចមួយ និងធំមួយ។
I have a small chisel and a big chisel.

[16:00]

*[លោកតា ក្រាក់ ជី ចិតករបស់អង្កួចបន្ថែម]*
*[KC carves the neck of an Angkuoch further.]*

[17:42]

*តើគាចូលចិត្តធ្វើបែបនេះទេ?*
*Do you like to make this instrument?*

[សើច...]
[Laughs...]

ឫស្សីនេះមិនសូវរលាស់!ខ្ញុំត្រូវធ្វើមួយទៀត ដើម្បីឱ្យវារលាស់ល្អ។
This bamboo cannot make a resonant sound. I will do another better one.

[18:24 - END]